# អនុក្រឹត្យលេខ ៥៨ អនក្រ.បក

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសំរប សំរួលការងារអប់រំក្រៅប្រព័ន្ធ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ [illegible]ហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩៩៧

## សំរេច

**មាត្រា ១.-** បង្កើតគណៈកម្មាធិការជាតិសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធ ដែលហៅកាត់ថា « គ.ជ.អ.ក.ប » ។

**មាត្រា ២ .-** គណៈកម្មាធិការនេះមានគោលបំណងសំរបសំរួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអោយបានល្អប្រសើរ ដើម្បីជំរុញការងារអប់រំក្រៅប្រព័ន្ធ ដែលរួមមានការបំបាត់អនក្ខរភាព ការផ្តល់ការអប់រំមូលដ្ឋាន និងការបណ្តុះបណ្តាលវិជ្ជាជីវៈអោយមានការរីកចំរើន រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកំពស់គុណភាពនៃ

ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ អភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ប្រទេសជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣ .-** សមាសភាពនៃគណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធរួមមាន ÷

១_ នាយករដ្ឋមន្ត្រី......................................ប្រធានកិត្តិយស
២_ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា .................. ប្រធាន
៣_ រដ្ឋលេខាធិការក្រសួងអប់ យុវជន និងកីឡា................អនុប្រធាន
៤_ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ........................... សមាជិក
៥_ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ........................... សមាជិក
៦_ តំណាងក្រសួងការពារជាតិ ................................ សមាជិក
៧_ តំណាងក្រសួងផែនការ... ................................ សមាជិក
៨_ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ....................... សមាជិក
៩_ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ............................ សមាជិក
១០_ តំណាងក្រសួងកិច្ចការនារី... ..............................សមាជិក
១១_ តំណាងក្រសួងសុខាភិបាល.. ..............................សមាជិក
១២_ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ............ សមាជិក
១៣_ តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន.......... សមាជិក
១៤_ តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ............... សមាជិក
១៥_ តំណាងក្រសួងបរិស្ថាន..... ................................ សមាជិក
១៦_ តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ...................... សមាជិក
១៧_ តំណាងក្រសួងពត៌មាន..... ................................ សមាជិក
១៨_ តំណាងក្រសួងធម្មការ និង កិច្ចការសាសនា................... សមាជិក

**មាត្រា ៤.-** គណៈកម្មាធិការជាតិសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ មាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និង កីឡា ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៥.-** គណៈកម្មាធិការជាតិសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធមានភារកិច្ច ÷

• រៀបចំគោលនយោបាយជាតិ ស្តីពីការអប់រំក្រៅប្រព័ន្ធ ។

- លើកផែនការ និងកំណត់គោលដៅនៃការអប់រំក្រៅប្រព័ន្ធ ។
- ដាក់ចុះនូវយុទ្ធសាស្ត្រសំរាប់ទ្រទ្រង់សកម្មភាពនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ ។
- សំរបសំរួល ទាក់ទង និង រៀបចំបង្កើតបណ្តាញជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ផ្នែកឯកជន និង សប្បុរសជន ដើម្បីចលនាប្រើប្រាស់ធនធាន ទាំងធនធានមនុស្ស ទាំងធនធានសំភារៈ និងថវិកាក្នុងការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ដោយអាចអញ្ជើញសមាសភាពពាក់ព័ន្ធទាំងនេះចូលរួមប្រជុំតាមការចាំបាច់ ។
- រៀបចំយុទ្ធសាស្ត្រសំរាប់ស្នើសុំការចូលរួមរបស់សហគមន៍ ។
- តាមដាន និងវាយតំលៃការរីកចំរើនរបស់ការងារអប់រំក្រៅប្រព័ន្ធ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមជនដែលជួបការលំបាក ។

**មាត្រា ៦.–** លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធមានភារកិច្ច ÷

- លើកកំពស់គុណភាព ប្រសិទ្ធភាពការងារបច្ចេកទេស សិក្សាស្រាវជ្រាវគោលនយោបាយអន្តរជាតិ និងបទពិសោធន៍ស្តីពីការងារអប់រំក្រៅប្រព័ន្ធ ។
- រៀបចំពង្រាងគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រផ្សេងៗដាក់ជូនគណៈកម្មាធិការជាតិសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ ។
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរ ជាតិដែលបាននិងកំពុងជួយទ្រទ្រង់យ៉ាងសកម្ម ដល់ការងារអប់រំក្រៅប្រព័ន្ធ ។
- រៀបចំការប្រជុំរបស់គណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ និងអនុវត្តរាល់សេចក្តីសំរេចចិត្ត របស់អង្គប្រជុំនៃគណៈកម្មាធិការនេះ ។

**មាត្រា ៧.–** នៅតាមបណ្តាខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ ត្រូវបង្កើតអោយមានគណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធថ្នាក់ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ ។

ក_សមាសភាពនៃគណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធខេត្ត/ក្រុង រួមមាន អភិបាលខេត្ត/ក្រុងជាប្រធាន ប្រធានមន្ទីរអប់រំយុវជន និងកីឡា ជា

អនុប្រធាន ប្រធានមន្ទីរពាក់ព័ន្ធជាសមាជិក ការិយាល័យអប់រំក្រៅប្រព័ន្ធជាលេខាធិការអចិន្ត្រៃយ៍ ។

ខ_សមាសភាពនៃគណៈកម្មាធិការសំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ ស្រុក/ខ័ណ្ឌ រួមមាន អភិបាលស្រុក/ខ័ណ្ឌជាប្រធាន ប្រធានការិយាល័យអប់រំ យុវជន និងកីឡាជាអនុប្រធាន ប្រធានការិយាល័យពាក់ព័ន្ធជាសមាជិក ផ្នែកអប់រំក្រៅប្រព័ន្ធជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

គ_សមាសភាពនៃគណៈកម្មាធិការ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធឃុំ/សង្កាត់ រួមមាន មេឃុំ/ចៅសង្កាត់ជាប្រធាន មន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ/សង្កាត់ ជាអនុប្រធាន នាយកកំរងសាលាបឋមសិក្សា និងមេភូមិ ជាសមាជិក ។

**មាត្រា ៨ .-** តួនាទី ភារកិច្ច និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការ ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ អាស្រ័យដោយគណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធជាអ្នកកំណត់ ។ គណៈកម្មាធិការសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ អាចអញ្ជើញអង្គការក្រៅរដ្ឋាភិបាល សមាគម ផ្នែកឯកជន និងសប្បុរសជន អោយចូលរួមអនុវត្តការងារនេះ ។

**មាត្រា ៩ .-** ថវិការបស់គណៈកម្មាធិការជាតិ សំរបសំរួលការងារអប់រំក្រៅប្រព័ន្ធ ត្រូវបានផ្តល់ដោយថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងការឧបត្ថម្ភពីប្រភពផ្សេងៗ។

**មាត្រា ១០.-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត/ក្រុង គណៈកម្មាធិការជាតិសំរបសំរួល ការងារអប់រំក្រៅប្រព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧**

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **អ៊ុង ហួត** | **ហ៊ុន សែន** |